# សុវត្ថិភាពក្នុងការងាររៀបចំដី

## (1) ការងារកាយដី

1. ពិនិត្យមើលការដ្ឋានមុននឹងចាប់ផ្ដើមការងារ។
- ពិនិត្យវត្តមានថ្មរង្គើ ថ្មធ្លាក់ និងស្នាមប្រេះ។
- បញ្ជាក់ពីបម្រែបម្រួលទឹកជ្រាបនិងទឹកបាញ់ចេញ។



- ពិនិត្យវត្តមានវត្ថុកប់ក្នុងដី ដូចជាបំពង់ទុយោឧស្ម័ននិង ខ្សែកាប្លិ៍អគ្គិសនីជាដើម។




2. យកកម្ទេចកម្ទីដីដែលអាចធ្លាក់ ហើយដំឡើងជញ្ជាំងទប់និងជន្ទល់។



3. ត្រូវបូមទឹកភ្លៀងនិងទឹកក្រោមដីចេញពីព្រោះវាអាចបណ្តាលឲ្យដួលរលំ។



4. ហាមជីកលុងទៅខាង។



5. ចូរប្រាកដថាបានចាត់តាំងអ្នកចាំណែនាំនៅពេលបំពេញការងារនៅជិតគ្រឿងចក្រ។



## (2) ការថយចាក់ដី

1. ចូរប្រាកដថាមានអ្នកចាំណែនាំនៅពេលបំពេញការងារនៅជិតគ្រឿងចក្រ។



2. ចៀសវាងចូលទៅកាន់ចំណុចកំបាំងរបស់គ្រឿងចក្រ។



3. ហាមពាក់សម្លៀកបំពាក់ដែលងាយទាក់ជាប់នឹងគ្រឿងចក្រ។
ហាមពាក់ក្រមាពោះគោនៅកឬចង្កេះ។



## (3) ការងាររៀបចំច្រាំង/កាត់ដី

1. ហាមទុកឬដាក់វត្ថុធ្ងន់នៅផ្នែកខាងលើទីជម្រាល។



2. របាររាំងនឹងត្រូវដំឡើងនៅផ្នែកខាងលើជម្រាលនិងស្មាផ្លូវដើម្បីការពារការធ្លាក់។



3. នៅពេលបំពេញការងារនៅលើទីជម្រាល ចូរពាក់ប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់)។



## (4) ការងារប្រព្រឹត្តិកម្មទឹក

1. ហាមចូលទៅជិតកន្លែងដែលអាចមានដីផុងឬបាក់ដី។



2. ប្រសិនបើលឺសំឡេងខុសប្រក្រតីចេញពីម៉ាស៊ីនបូមឬបំពង់បូម ចូររាយការណ៍ដល់មេការដោយមិនចាំបាច់ចូលទៅជិតវាឡើយ។



## ( 5 ) ការងារចាក់បេតុង

1. ចូរប្រយ័ត្នកុំស្ថិតនៅជិតបរិវេណគ្រឿងចក្រដែលកំពុងវិលដូចជាម៉ាស៊ីនក្រឡុកបេតុងជាដើម។



2. នៅពេលដើរនៅលើរបារដែករវែង ចូរប្រយ័ត្នជំពប់ជើង ដួល ឬទាក់ជាប់សម្លៀកបំពាក់។



3. ប្រយ័ត្នក្រែងលោធ្លាក់ពីលើរន្ទាចាក់បេតុង។ នៅកន្លែងដែលមានកម្ពស់ 2 ម៉ែត្រ ឬខ្ពស់ជាងនេះ ចូរប្រើប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់)។



4. ចូរប្រាកដថាស៊ីម៉ង់ត៍ដែលលាយរួចមិនខ្ទាយនិងស្អិតជាប់ស្បែកឬចូលភ្នែក។



5. នៅពេលប្រើម៉ាស៊ីនរំញ័របេតុង។ល។
ទាល់តែមានការបណ្តុះបណ្តាល។



## (6) កិច្ចការដែលត្រូវធ្វើដោយមេការ (ពាក់ព័ន្ធតែនឹងការងាររៀបចំដីប៉ុណ្ណោះ)

1. ការកាយដីធម្មជាតិនិងការទប់ដី
2. កង្វះអុកស៊ីហ្សែន/អ៊ីដ្រូហ្សែនស៊ុលហ្វីដ
3. ការដំឡើងរន្ទា។ល។
4. ការដំឡើង ។ល។នៃជន្ទល់ទ្រគ្រោងបេតុង
5. ការកាយទូណែល ។ល។
6. ការងារផ្ទុកដុំសម្ភារ




## (7) ធាតុដែលត្រូវការការបណ្តុះបណ្តាល/ហ្វឹកហាត់សម្រាប់បើកបរ/ប្រតិបត្តិការ/ប្រើប្រាស់ (ពាក់ព័ន្ធតែនឹងការងាររៀបចំដីប៉ុណ្ណោះ)

1. ប្រតិបត្តិការគ្រឿងចក្រស្ថាបនាប្រភេទយានយន្ត
2. ប្រតិបត្តិការដងសន្ទូច
3. ប្រតិបត្តិការរថយន្តសន្ទូចចល័ត
4. ការងារស្ទូចយោង
5. ការដំឡើងរន្ទា។ល។
6. ប្រតិបត្តិការរថយន្តផ្លែតហ្វមការងារខាងលើ
7. ប្រតិបត្តិការគ្រឿងចក្រលើក
8. ការប្រើប្រាស់ឧបករណ៍ញញួរ
9. ប្រតិបត្តិការរថយន្តផ្ទេរនៅលើផ្លូវរលាក់
10. ប្រតិបត្តិការរ៉ូឡូកិនបង្ហាប់ថ្នល់
11. ប្រតិបត្តិការកង្វះអុកស៊ីហ្សែន/អ៊ីដ្រូហ្សែនស៊ុលហ្វីដ
12. ប្រតិបត្តិការកាយដីផ្លូវទូណែល។ល។




